# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាជាមួយសភាលោកអភិបាលឡាវ-កម្ពុជា នៅចំណោម
# ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៨
## *តើយើងមានសេចក្ដីក្លាហានដូចមរណសាក្សីទេឬ?*

អត្ថបទទី១៖ ១ករ ១៥,១-១១
ដំណឹងល្អ៖ លក ៧,៣៦-៥០

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាថ្ងៃដែលយើងនឹករឭកដល់មរណសាក្សីនៃប្រទេសកូរ៉េ ធ្វើឲ្យយើងនឹកឃើញដល់មរណសាក្សីនៅប្រទេសកម្ពុជាផង និងមរណសាក្សីនៅប្រទេសឡាវផង។ នេះទីនេះយើងមានលោកកាឌីណាល់ លោកអភិបាល លោកបូជាចារ្យ មកពីប្រទេសឡាវ ដែលព្រះសហគមន៍បានទទួលស្គាល់មរណសាក្សី១៧នៅប្រទេសនេះ ដែលបានស្លាប់នៅសម័យកុម្មុយនីស្ដ ពួកគេសុខចិត្តបូជាជីវិតសម្រាប់ព្រះសហគមន៍។ នៅទីនេះយើងមានលោកកាឌីណាល់លីង និងលោកអភិបាលតឺតូ ទាំងពីរនាក់ជាមរណសាក្សីដ៏មានជីវិត ដែលបានសុខចិត្តលះបង់អ្វីៗទាំងអស់សម្រាប់ជំនឿរបស់គេ។ គាត់ទាំងពីរនាក់បានជាប់ពន្ធនាគារ(គុក)ជាច្រើនឆ្នាំ លោកតឺតូ ៩ឆ្នាំ លោកលីង ៣ឆ្នាំ នៅក្នុងសម័យកុម្មុយនីស្ដ។ ពួកគាត់បានតស៊ូដោយសារជំនឿ និងដោយសារពួកគាត់ដឹងថាព្រះជាម្ចាស់ស្រឡាញ់ពួកគាត់។

ពេលយើងមកដល់ចំណោម យើងដឹងភ្លាមលោកឪពុក ចនម៉ាជ្រេ ដែលបានដឹកនាំព្រះសហគមន៍នៅទីនេះ បានធ្វើឲ្យបងប្អូនគ្រីស្ដបរិស័ទសម័យនោះស្រឡាញ់គាត់ណាស់។ គាត់បានស្លាប់នៅជិតផ្សារមង្គលបូរីជាមួយលោកអភិបាល ទេពអ៊ីម។ ថ្ងៃនេះខ្ញុំពាក់ឈើឆ្កាងរបស់លោកអភិបាលឆ្មារ សាឡាស់ ដែលម្ដាយរបស់គាត់បានលាក់ទុកក្នុងសំបុកមាន់ដើម្បីកុំឲ្យពួកខ្មែរក្រហមរកឃើញ ហើយបានបន្តដល់លោកអភិបាលភូមិភាគភ្នំពេញរហូតមកដល់ខ្ញុំ។ នេះជាសាក្សីបញ្ជាក់អំពីជីវិតរបស់មរណសាក្សីនៅប្រទេសកម្ពុជារបស់យើង។

ពេលយើងនឹកឃើញដល់មរណសាក្សីដ៏មានជីវិត មរណសាក្សីនៅប្រទេសឡាវ មរណសាក្សីនៅប្រទេសកម្ពុជា មរណសាក្សីនៅប្រទេសកូរ៉េរាប់មឺននាក់។ នៅប្រទេសកូរ៉េ មានគេប្រាប់គ្រីស្ដបរិស័ទថា បើសុខចិត្តលះបង់ចោលជំនឿ សុខចិត្តនិយាយអាក្រក់អំពីព្រះយេស៊ូ ពួកគេមានជីវិត ប៉ុន្តែប្រសិនបើបន្តដើរតាមព្រះយេស៊ូ និងប្រកាសជំនឿតទៅទៀតពួកគេនឹងត្រូវស្លាប់។ គេបានសម្លាប់គ្រីស្ដបរិស័ទជាងមួយមឺននាក់ ដែលមិនព្រមលះបង់ចោលជំនឿ ដោយយកថ្មមកបោកនឹងក្បាល ឬទំលាក់ចូលនៅក្នុងទឹក។

ថ្ងៃនេះ ព្រះយេស៊ូបង្ហាញនៅក្នុងគម្ពីរដំណឹងល្អអំពីសេចក្តីស្រឡាញ់ មរណសាក្សីទាំងអស់គេមិនបានត្រៀមខ្លួនមុនដើម្បីស្លាប់ទេ គេរស់នៅធម្មតា គេអធិដ្ឋាន គេចូលព្រះវិហារជួនកាលមានគេភ្លេចព្រះជាម្ចាស់ដែរ ក៏ប៉ុន្តែគេដឹងថាព្រះជាម្ចាស់ស្រឡាញ់គេ។ ថ្ងៃនេះ លោកសិលា គាត់ឆ្ងល់ពេលគាត់ឃើញរបៀបដែលព្រះយេស៊ូស្រឡាញ់ ស្ត្រីដែលពោរពេញដោយអំពើបាប បានយំនិងយកទឹកក្រអូបថ្លៃៗយកមកលាងជើងឲ្យព្រះយេស៊ូ ហើយជូតជើងរបស់ព្រះយេស៊ូជាមួយសក់របស់នាង និងថើបព្រះបាទារបស់ព្រះយេស៊ូថែមទៀតដើម្បីបង្ហាញថាគាត់ស្រឡាញ់ព្រះយេស៊ូខ្លាំងណាស់។ មនុស្សយើងមើលងាយគាត់ ប៉ុន្តែនៅពេលគាត់បានលាងជើងរបស់ព្រះយេស៊ូ ព្រះអង្គមិនបានបណ្តេញគាត់ទេ ព្រះយេស៊ូនៅសកវាគមន៍គាត់ ធ្វើឲ្យអ្នកនៅជុំវិញគេឆ្ងល់ មូលហេតុអ្វីព្រះយេស៊ូស្វាគមន៍ស្ត្រីដែលពោរពេញដោយអំពើបាបដូចនេះ? ស្ត្រីនោះបានយល់អំពីសេចក្តីស្រឡាញ់ដ៏ទូលំទូលាយរបស់ព្រះជាម្ចាស់ ពេលគាត់ហ៊ាននៅជិតព្រះយេស៊ូដោយសារគាត់យល់ថាព្រះយេស៊ូមិនបណ្តេញគាត់ ព្រះយេស៊ូនឹងស្វាគមន៍គាត់ដោយសារព្រះយេស៊ូយាងមកដើម្បីណែនាំឲ្យអ្នកជំងឺជាសះស្បើយ ឲ្យអ្នកដែលអស់សង្ឃឹមរកឃើញសេចក្តីសង្ឃឹមវិញ។ ពេលយើងមានជំងឺយើងទៅពេទ្យ នៅពេលយើងមានបាបនៅក្នុងខ្លួនយើងទៅជួបលោកបូជាចារ្យដើម្បីទទួលជីវិតថ្មី និងដើម្បីទទួលបទពិសោធន៍អំពីព្រះជាម្ចាស់ដែលស្រឡាញ់យើងខ្លាំងណាស់។

ថ្ងៃនេះ នៅពេលយើងឃើញមរណសាក្សីទាំងអស់ និងជីវិតរបស់យើងជាគ្រីស្តបរិស័ទយើងយល់ថាប្រភពកម្លាំងនៃជីវិតរបស់យើង គឺសេចក្តីស្រឡាញ់ដែលព្រះជាម្ចាស់មានសម្រាប់យើង។ បើថ្ងៃណាមួយមានគេមកបៀតបៀនយើងដូចនៅប្រទេសកូរ៉េសម័យនោះ តើយើងឆ្លើយអ្វីខ្លះ? តើយើងមានសេចក្តីក្លាហានដូចមរណសាក្សីទាំងអស់ថា ពិតមែនខ្ញុំស្រឡាញ់ព្រះអង្គខ្លាំងណាស់។ ជីវិតរបស់យើងពីមួយថ្ងៃទៅមួយថ្ងៃ ណែនាំឲ្យព្រះយេស៊ូពេញចិត្តជាមួយយើងដែរ នេះជាជីវិតរបស់យើងជាគ្រីស្តបរិស័ទ។ យើងយកចិត្តទុកដាក់ឲ្យព្រះជាម្ចាស់ដែលស្រឡាញ់យើងពោរពេញដោយអំណរសប្បាយដោយសាររបៀបដែលយើងរស់នៅ ដោយសាររបៀបដែលយើងស្រឡាញ់ របៀបដែលយើងបម្រើ របៀបរស់នៅធម្មតារបស់យើង។

ថ្ងៃនេះយើងរួមគ្នាអរព្រះគុណព្រះសហគមន៍ ដែលបានណែនាំឲ្យយើងទទួលព្រះជាម្ចាស់ជាព្រះបិតារបស់យើង ដោយដឹងថាយើងជាបុត្រធីតារបស់ព្រះអង្គ។ សូមព្រះអង្គណែនាំឲ្យយើងមានជំនឿថែមទៀត សេចក្តីស្រឡាញ់ថែមទៀត សេចក្តីសង្ឃឹមថែមទៀត ដោយនឹកឃើញដល់បុព្វបុរសរបស់យើងដែលបានបូជាជីវិត ដែលបានលះបង់ចោលដើម្បីឲ្យព្រះសហគមន៍របស់យើងសព្វថ្ងៃមានជីវិតដ៏បរិបូរណ៍។ យើងអរព្រះគុណព្រះជាម្ចាស់ សម្រាប់ជីវិតដែលយើងបាន

ទទួលជារៀងរាល់ថ្ងៃឲ្យយើងនឹកឃើញវត្តមានរបស់ព្រះជាម្ចាស់ ដោយសារព្រះជាម្ចាស់គង់នៅជាមួយយើងជានិច្ច ដើម្បីណែនាំឲ្យយើងពោរពេញដោយដោយសុភមង្គល។ អាម៉ែន៕